ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
## ទីក្រុងវៀងច័ន្ទន៍ ថ្ងៃទី ១៣-១៤ ខែកុម្ភៈ ឆ្នាំ២០២៣

======

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២៣ - តបតាមការអញ្ជើញរបស់**ឯកឧត្តម សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ បំពេញទស្សនកិច្ចផ្លូវការ នៅវៀងច័ន្ទន៍ ពីថ្ងៃទី១៣-១៤ ខែកុម្ភៈ ឆ្នាំ២០២៣។

ក្នុងអំឡុងពេលស្នាក់នៅ **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងដាក់កម្រងផ្កានៅវិមានយុទ្ធជនមិនស្គាល់អត្តសញ្ញាណដែលបានពលីនៅក្នុងសង្គ្រាម។ ទន្ទឹមនេះ **សម្តេចតេជោ** ក៏បានចូលជួបសម្តែងការគួរសមដាច់ដោយឡែកពីគ្នាជាមួយ **ឯកឧត្តម ថងលុន ស៊ីសុលីត** ប្រធានរដ្ឋឡាវ នៅវិមានប្រធានរដ្ឋ និង**ឯកឧត្តមបណ្ឌិត សាយសំផន គុមវិហាន** ប្រធានរដ្ឋសភាឡាវ នៅវិមានរដ្ឋសភា។

**សម្តេចតេជោ** និង**ឯកឧត្តម សនសៃ ស៊ីផាន់ដន** បានជួបពិភាក្សាគ្នាយ៉ាងស៊ីជម្រៅអំពីស្ថានភាពនៃទំនាក់ទំនងទ្វេភាគី និងទិសដៅអនាគតដើម្បីបន្តពង្រឹងចំណងមិត្តភាពជាប្រពៃណី ទំនាក់ទំនងដ៏ជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យជាច្រើន រួមមានៈ នយោបាយ-សន្តិសុខ ការពារជាតិ កិច្ចការព្រំដែន ពាណិជ្ជកម្ម និងវិនិយោគ ការតភ្ជាប់ផ្លូវអាកាស ទេសចរណ៍ ថាមពល និងការអប់រំ។

ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តនូវកំណើនពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងឡាវ ដែលមានសន្ទុះជាវិជ្ជមានកើនឡើងពី ១៦០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ទៅ ២១០លានដុល្លារអាមេរិក នៅឆ្នាំ២០២២។ **សម្តេចតេជោ** បានលើកទឹកចិត្តឲ្យភាគីទាំងពីរពន្លឿនការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការរៀបចំព្រឹត្តិការណ៍ផ្គូផ្គងដៃគូពាណិជ្ជកម្ម ការតាំងពិព័រណ៍ និងសិក្ខាសាលា ដើម្បីផ្តល់ឱកាសកាន់តែច្រើនសម្រាប់ការផ្លាស់ប្តូរពាណិជ្ជកម្ម

វិនិយោគ និងដើម្បីជំរុញបន្ថែមទៀតនូវពាណិជ្ជកម្មទ្វេភាគី វិនិយោគ និងសកម្មភាពសេដ្ឋកិច្ចនានារវាងប្រទេសទាំងពីរ។

នាយករដ្ឋមន្ត្រីទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់នៃ**វិស័យទេសចរណ៍**ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ភាគីទាំងពីរបានស្វាគមន៍ការបើកឡើងវិញនូវជើងហោះហើរត្រង់ពីហ្លួងប្រាបាង-ប៉ាកសេ-សៀមរាប ដោយក្រុមហ៊ុនអាកាសចរណ៍ឡាវ។ **សម្តេចតេជោ** លើកទឹកចិត្តឲ្យបើកនូវការហោះហើរត្រង់ពីភ្នំពេញ-វៀងច័ន្ទន៍-ភ្នំពេញឡើងវិញ ខណៈដែលប្រទេសទាំងពីរបានបើកប្រទេសទាំងស្រុងវិញហើយ។

**ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ** នាយករដ្ឋមន្ត្រីទាំងពីរបានជំរុញឲ្យភាគីទាំងពីរបន្តធ្វើការផ្លាស់ប្តូរបញ្ញវន្ត អ្នកស្រាវជ្រាវ បោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ និងចែករំលែកចំណេះដឹង និងស្រាវជ្រាវរវាង រាជបណ្ឌិតសភាកម្ពុជា និងបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមឡាវ។ នាយករដ្ឋមន្ត្រីទាំងពីរបានជម្រុញឲ្យភាគីទាំងពីរពន្លឿនការបញ្ចប់ការស្រាវជ្រាវរួមគ្នាស្តីពី «**ទំនាក់ទំនងកម្ពុជា-ឡាវៈ ទំនាក់ទំនងប្រវត្តិសាស្ត្រ វប្បធម៌ និងប្រជាជននៅតាមព្រំដែននៃប្រទេសទាំងពីរ**» និងការរៀបចំវចនានុក្រម ឡាវ-ខ្មែរ និងខ្មែរ-ឡាវ។

**ចំពោះវិស័យសន្តិសុខ និងការពារជាតិ** ភាគីទាំងពីរបានឯកភាពពង្រឹង កិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន តាមរយៈការចែករំលែកព័ត៌មានឲ្យបានទាន់ពេលវេលារវាងអាជ្ញាធរនៅតាមតំបន់ព្រំដែន។ **សម្តេចតេជោ** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្តធ្វើលំហាត់រួមសង្គ្រោះគ្រោះមហន្តរាយតាមបណ្តាខេត្តជាប់ព្រំដែន។

**ចំពោះកិច្ចការព្រំដែន** នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍វឌ្ឍនភាពដែលគណៈកម្មាការចម្រុះព្រំដែនកម្ពុជា និងឡាវ សម្រេចបានក្នុងការកំណត់ខ្សែព្រំដែនរួមបានប្រមាណ ៨៦% រួមមានការបោះបង្គោលព្រំដែនលើដីជាក់ស្តែងបានចំនួន ១២១ បង្គោល។

នាយករដ្ឋមន្ត្រីទាំងពីរបានទទួលស្គាល់សារៈសំខាន់នៃ**វិស័យថាមពល**ដែលជាស្នូលអាទិភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា និងឡាវ។ ភាគីទាំងពីរបានលើកទឹកចិត្តឲ្យក្រសួង/ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុស្សរណៈយោគយល់គ្នានិងកិច្ចព្រមព្រៀងនានាដែលមានស្រាប់ ស្តីពីកិច្ចសហប្រតិបត្តិការថាមពលរវាងប្រទេសទាំងពីរ សំដៅធានាស្ថិរភាព និងសន្តិសុខថាមពលដើម្បីការអភិវឌ្ឍជាតិ។

**ចំពោះកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ សម្តេចតេជោ**បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលឡាវដែលបានគាំទ្រយ៉ាងសកម្មដល់ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជាឆ្នាំ២០២២ និងបានបញ្ជាក់សាជាថ្មីពីការគាំទ្រយ៉ាងពេញទំហឹងរបស់កម្ពុជា ចំពោះការធ្វើជាប្រធានអាស៊ានរបស់ឡាវឆ្នាំ២០២៤។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានឯកភាពបន្តគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាតំបន់ និងអន្តរជាតិ ជាពិសេសក្នុងក្របខណ្ឌអាស៊ាន និងអង្គការសហប្រជាជាតិ។

ក្នុងឱកាសទស្សនកិច្ចផ្លូវការរបស់**សម្តេចតេជោ** នាយករដ្ឋមន្ត្រីទាំងពីរបានចុះហត្ថលេខាលើឯកសារជាប្រវត្តិសាស្ត្រសំខាន់ចំនួន ០២ រួមមាន៖ **១-សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ២-ផែនការសកម្មភាពសម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** (២០២៣-២០២៧)។ ទន្ទឹមនេះដែរ នាយករដ្ឋមន្ត្រីទាំងពីរបានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើ**កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា** ដោយឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និង**ឯកឧត្តម សាលើមសៃ គុំម៉ាស៊ីត** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការបរទេស និងជាប្រធានគណៈកម្មការចម្រុះព្រំដែនឡាវ។

ដើម្បីជាសក្ខីភាពនៃការទទួលស្គាល់នូវគុណបំណាច់ និងការចូលរួមចំណែកដ៏ធំធេងរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការលើកកម្ពស់ទំនាក់ទំនងមិត្តភាពដ៏ល្អប្រសើរ និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងឡាវ ជាពិសេសការតម្លើងកម្រិតទំនាក់ទំនងទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង **ឯកឧត្តម ថងលុន ស៊ីសុលីត** ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានបំពាក់គ្រឿងឥស្សរិយយស មេដាយ "**ផូសៃឡានសាង**" (MEDAL PHOXAY LANE XANG) ជូន**សម្តេចតេជោ**។ មេដាយ **«ផូសៃឡានសាង»** ជាមេដាយមានគុណតម្លៃខ្ពស់បំផុតរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្រាប់បំពាក់ជូនថ្នាក់ដឹកនាំបរទេសដែលមានស្នាដៃលេចធ្លោ។ **ឯកឧត្តម សនសៃ ស៊ីផាន់ដន** ក៏បានបំពាក់មេដាយអភិវឌ្ឍន៍ជូនដល់ក្រុមហ៊ុនឯកជនកម្ពុជាមួយចំនួន ដែលបានរួមចំណែកជួយរដ្ឋាភិបាលឡាវ ក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ក្នុងប្រទេសឡាវកន្លងមក និងមេដាយមិត្តភាពជូនសមាគមមិត្តភាពកម្ពុជា-ឡាវផងដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញ**ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងភរិយា មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាក្នុងពេលឆាប់ៗខាងមុខ។ **ឯកឧត្តម នាយករដ្ឋមន្ត្រីឡាវ** បានថ្លែងអំណរគុណ និងទទួលយកការអញ្ជើញ ដោយក្តីរីករាយ។ ពេលវេលាជាក់លាក់នៃដំណើរទស្សនកិច្ចនេះនឹងត្រូវរៀបចំតាមរយៈផ្លូវការទូតនៅពេលក្រោយ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរដ្ឋាភិបាល និងប្រជាជនឡាវសម្រាប់ការផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជូនគណៈប្រតិភូជាន់ខ្ពស់កម្ពុជា។

**សម្តេចតេជោ** ក៏បានទទួលជំនួបសម្តែងការគួរសមពីលោកប្រធានសមាគមមិត្តភាពឡាវ-កម្ពុជា និងបានជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជានៅឡាវផងដែរ៕